ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ២៧ អយក.សណន

# សេចក្តីណែនាំ
# ស្តីពី
# ការបង្រៀន និងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក សម្រាប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ ឆ្នាំសិក្សា២០២០-២០២១

ដើម្បីធានាបាននូវការបន្តការសិក្សារបស់សិស្សានុសិស្សនៅមធ្យមសិក្សា ក្នុងពេលដែលសាលារៀនផ្អាកដំណើរការ គ្រឹះស្ថានមធ្យមសិក្សាសាធារណៈនៅទូទាំងប្រទេស អាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀន និងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក ឬរៀនតាមបណ្តុំតូចៗ អាស្រ័យលើស្ថានភាព និងធនធាន ក្រោមការថ្លៃប្រឌិតរបស់លោកគ្រូ អ្នកគ្រូនៅតាមមូលដ្ឋាន។ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្តអាចចេញសេចក្តីណែនាំបន្ថែមស្តីពីការអនុវត្តសេចក្តីណែនាំរួមនេះ ទៅតាមស្ថានភាពជាក់ស្តែងនៃមូលដ្ឋានរបស់ខ្លួន។

ក្នុងន័យនេះ ក្រសួងសូមធ្វើការណែនាំដល់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈ មាតាបិតា អ្នកអាណាព្យាបាល សិស្សានុសិស្ស ព្រមទាំងគណៈកម្មការគ្រប់គ្រងសាលារៀន /គណៈកម្មការទ្រទ្រង់សាលារៀន ស្តីពីការបន្តដំណើរការបង្រៀននិងរៀនពីចម្ងាយនិងតាមប្រព័ន្ធអេឡិចត្រូនិក ដូចខាងក្រោម៖

## ១- ការកែសម្រួលប្រតិទិនសិក្សា ឆ្នាំសិក្សា២០២០២០២១-

យោងសេចក្តីណែនាំលេខ ៦០ អយក.សណន ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ និងសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ ឆ្នាំសិក្សា២០២០-២០២១ ត្រូវបើកបវេសនកាលនាថ្ងៃទី១១ ខែមករា ឆ្នាំ២០២១ និងបញ្ចប់ទៅវិញ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ក្រសួងសូមធ្វើការកែសម្រួលប្រតិទិនសិក្សា ដូចខាងក្រោម៖

- ឆ្នាំសិក្សា២០២០-២០២១ ត្រូវចាប់ផ្តើមនៅថ្ងៃទី១១ ខែមករា ឆ្នាំ២០២១
- ឆមាសទី១ គិតចាប់ពីខែមករា ដល់ខែឧសភា ឆ្នាំ២០២១
- ឆមាសទី២ គិតចាប់ពីខែមិថុនា ដល់ខែវិច្ឆិកា ឆ្នាំ២០២១
- វិស្សមកាលធំ ចាប់ពីថ្ងៃទី០១ដល់ ៣១ ខែធ្នូ ឆ្នាំ២០២១។

## ២- ការអនុវត្តកម្មវិធីសិក្សាបង្រួញ

គ្រប់គ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវបន្តដំណើរការបង្រៀននិងរៀន តាមរយៈការអនុវត្តកម្មវិធីសិក្សាបង្រួញ ដោយផ្តោតលើមុខវិជ្ជាកាតព្វកិច្ចដូចខាងក្រោម៖

**២.១. ថ្នាក់ទី៧និងថ្នាក់ទី៨៖** ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា សីលធម៌-ពលរដ្ឋវិទ្យា និងភាសាបរទេស ដែលមុខវិជ្ជាទាំង៨នេះ អនុវត្តទាំងស្រុងតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា

**២.២. ថ្នាក់ទី១០៖** ភាសាខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ប្រវត្តិវិទ្យា និងសីលធម៌-ពលរដ្ឋវិទ្យា និងភាសាបរទេស ដែលមុខវិជ្ជាទាំង៨នេះ អនុវត្តទាំងស្រុងតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា

**២.៣. ថ្នាក់ទី១១(ថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)៖** អក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ភាសាបរទេស និងព័ត៌មានវិទ្យា ដែលមុខវិជ្ជាទាំង៨នេះ អនុវត្តទាំងស្រុងតាមកម្មវិធីសិក្សាគោលរបស់ក្រសួងអប់រំ យុវជន និងកីឡា

**២.៤. ថ្នាក់ទី៩ និងថ្នាក់ទី១២(ថ្នាក់វិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម)៖** ភាសាខ្មែរ/អក្សរសាស្ត្រខ្មែរ គណិតវិទ្យា រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា ផែនដីនិងបរិស្ថានវិទ្យា ប្រវត្តិវិទ្យា ភូមិវិទ្យា សីលធម៌-ពលរដ្ឋវិទ្យា និងភាសាបរទេស (ព្រមទាំងមុខវិជ្ជាព័ត៌មានវិទ្យា ប្រសិនអាចមានលទ្ធភាព)។

**គ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវ៖**

- រៀបចំផែនការបង្រៀនប្រចាំសប្តាហ៍ និងប្រចាំខែឡើងវិញ ដោយផ្តោតលើខ្លឹមសារមេរៀនសំខាន់ៗ ដែលជាមូលដ្ឋានគ្រឹះក្នុងការបន្តការសិក្សានៅថ្នាក់បន្តបន្ទាប់ទៀត
- សង្ខេបខ្លឹមសារមេរៀនដោយផ្តោតលើបញ្ញត្តិដែលធ្វើឱ្យសិស្សងាយយល់ និងអាចយកទៅ អនុវត្តបាន
- លើកទឹកចិត្តនិងជួយសិស្សឱ្យអនុវត្តសំណួរ លំហាត់ ចំណោទ ធ្វើការហ្វឹកហាត់ឱ្យបានញឹកញាប់បន្ថែមទៀតនៅផ្ទះ
- មុខវិជ្ជាផ្សេងទៀតក្រៅពីមុខវិជ្ជាកាតព្វកិច្ចត្រូវផ្សព្វផ្សាយ ដោយនឹងត្រូវរៀនបំពេញបន្ថែមនៅដើមឆ្នាំសិក្សាបន្ទាប់។

## ៣. វិធានការដើម្បីបន្តដំណើរការបង្រៀននិងរៀន

អាជ្ញាធរដែនដី ជាពិសេសអភិបាលនៃគណៈអភិបាលខេត្ត ឬក្រុង ស្រុក ត្រូវធ្វើការកំណត់តំបន់ដែលមានហានិភ័យទាប (ពណ៌លឿង) ហានិភ័យមធ្យម (ពណ៌លឿងទុំ) និងហានិភ័យខ្ពស់ (ពណ៌ក្រហម) ទៅតាមទំហំនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

រាជធានីភ្នំពេញ និងតំបន់ដែលត្រូវបានកំណត់ជាតំបន់មានហានិភ័យខ្ពស់ និងមធ្យម (ពណ៌ក្រហម និងពណ៌លឿងទុំ) ត្រូវអនុវត្តការបង្រៀននិងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិកទាំងស្រុង។

តំបន់ដែលមានហានិភ័យទាប (ពណ៌លឿង) គណៈគ្រប់គ្រងសាលាអាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនជាក្រុមតូចៗ (សិស្សមិនលើសពី១០នាក់ ក្នុង១បណ្តុំ) នៅតាមផ្ទះ ឬទីតាំងសមស្របណាមួយ សម្រាប់សិស្សដែលមានលំនៅដ្ឋាននៅជិតៗគ្នា និងធ្លាប់មានទំនាក់ទំនងគ្នាជាប្រចាំ។ មន្ទីរអប់រំ យុវជន និងកីឡាខេត្តត្រូវរៀបចំសំណើ ដាក់ឆ្លងយោបល់សម្រេចពីគណៈអភិបាលក្រុង ស្រុក និងគណៈអភិបាលខេត្ត ព្រមទាំងផ្ញើមកក្រសួងអប់រំ យុវជន និងកីឡា។

នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅបានផលិតឯកសារគ្រប់មុខវិជ្ជា គ្រប់កម្រិតថ្នាក់ជាវីដេអូសិក្សា និងសន្លឹកកិច្ចការ ប្រភេទ១ និងប្រភេទ២ សម្រាប់សិស្សស្វ័យសិក្សា ដើម្បីធានាបានគុណភាពសម្រាប់ សកម្មភាពរៀន និងបង្រៀនពីចម្ងាយឆ្លើយតបទៅ នឹងស្តង់ដាលទ្ធផល កម្មវិធីសិក្សាលម្អិតនៃមុខវិជ្ជា និងកម្រិតថ្នាក់។

- គ្រឹះស្ថានមធ្យមសិក្សាសាធារណៈទូទាំងប្រទេសបន្តអនុវត្តកាបង្រៀន និងរៀនពីចម្ងាយ តាមរយៈសន្លឹកកិច្ចការ និងប្រព័ន្ធអេឡិចត្រូនិកទៅតាមលទ្ធភាពរបស់សាលារៀននីមួយៗ

- ណែនាំឱ្យលោកគ្រូ អ្នកគ្រូធ្វើទំនាក់ទំនងជាប្រចាំជាមួយមាតាបិតាសិស្ស ឬអ្នកអាណាព្យាបាល តាមរយៈការផ្ញើសារតាមទូរស័ព្ទMessenger ឬTelegram
- ផ្សព្វផ្សាយឱ្យលោកគ្រូ អ្នកគ្រូជូនដំណឹងដល់មាតាបិតា ឬអ្នកអាណាព្យាបាលសិស្សតម្លើង MoEYS E-Learning App ដើម្បីឱ្យកូនៗបានសិក្សានៅផ្ទះ
- សហការជាមួយអាជ្ញាធរដែនដី ភូមិ ឃុំ ក្នុងការបែងចែកសន្លឹកកិច្ចការ និងផ្តល់សន្លឹកកិច្ចការត្រឡប់មកសាលារៀនវិញ
- សហការជាមួយនាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ក្នុងការបញ្ចូលវីដេអូការបង្រៀនកាលពីឆមាសទី១
- បន្តផលិត និងផ្តល់សន្លឹកកិច្ចការសម្រាប់ផ្តល់ឱ្យសិស្សតាមរយៈតេឡេក្រាម។

## ៣.១ កិច្ចការរបស់គ្រឹះស្ថានសិក្សា

- រៀបចំបែងចែកភារកិច្ចគណៈគ្រប់គ្រងសាលារៀន ឱ្យទទួលបន្ទុកពិនិត្យតាមដានការបង្រៀន និងរៀនគ្រប់មុខវិជ្ជា និងគ្រប់កម្រិតថ្នាក់តាមប្រព័ន្ធអេឡិចត្រូនិច និងតាមសន្លឹកកិច្ចការ
- រៀបចំក្រុមតេឡេក្រាមជាមួយគ្រូបង្រៀនតាមថ្នាក់រៀន និងតាមមុខវិជ្ជា
- បញ្ជូនវីដេអូសិក្សា និងសន្លឹកសិក្សាសម្រាប់សិស្សស្វ័យសិក្សាទៅគ្រូបង្រៀន សិស្ស និងមាតាបិតាតាមតេឡេក្រាម ឬមធ្យោបាយផ្សេងទៀត
- ធ្វើការផ្សព្វផ្សាយតាមមធ្យាបាយផ្សេងៗឱ្យដល់មាតាបិតា សិស្សានុសិស្សអំពីការរៀនសូត្រតាមបរិបទថ្មី
- ពិនិត្យតាមដានការអនុវត្តការងាររបស់គ្រូបង្រៀន និងគ្រូទទួលបន្ទុកថ្នាក់តាមម៉ោងបង្រៀន និងការធ្វើតេស្តឬប្រឡងប្រចាំខែតាមមុខវិជ្ជានីមួយៗ។

## ៣.២ កិច្ចការរបស់គ្រូបង្រៀន និងគ្រូទទួលបន្ទុកថ្នាក់

- រៀបចំក្រុមតេឡេក្រាមតាមក្រុមមុខវិជ្ជាងាយស្រួលក្នុងការបង្រៀន ការប្រជុំក្រុមបច្ចេកទេសតាមប្រព័ន្ធអេឡិចត្រូនិច និងរាយការណ៍ជូនគណៈគ្រប់គ្រងសាលារៀនប្រចាំខែ
- រៀបចំក្រុមតេឡេក្រាមតាមក្រុមមុខវិជ្ជា និងរាយការណ៍ជូនគណៈគ្រប់គ្រងសាលារៀន
- ធានាថាសិស្ស និងមាតាបិតាបានទទួលព័ត៌មានស្តីពីការសិក្សាតាមសន្លឹកកិច្ចការ និងវីដេអូ
- ជួបសិស្ស មាតាបិតា អាជ្ញាធរ ភូមិ ឃុំប្រចាំសប្តាហ៍ ដើម្បីទទួលសន្លឹកកិច្ចការសម្រាប់សិស្សស្វ័យសិក្សា និងប្រគល់មកវិញនៅចុងសប្តាហ៍ឬសប្តាហ៍បន្ទាប់ និងធានាបានការរក្សានូវអនាម័យតាមការណែនាំរបស់ក្រសួងសុខាភិបាល
- កែសន្លឹកកិច្ចការសិស្ស កែលម្អសំណួរ ចម្លើយ ជួយសិស្សរៀនយឺតដោះស្រាយសិស្សមានចម្ងល់លើខ្លឹមសារមេរៀន។

## ៣.៣ កិច្ចការរបស់មាតាបិតា ឬអ្នកអាណាព្យាបាល អាជ្ញាធរ ភូមិ ឃុំ

- បង្កើតក្រុមតេឡេក្រាមផ្ទាល់ខ្លួនតាមថ្នាក់ ដែលកូនបានរៀនជាមួយគ្រូ
- ទៅគ្រឹះស្ថានសិក្សារាល់សប្តាហ៍ ឬតាមថ្ងៃកំណត់(ថ្ងៃប្រគល់ និងថ្ងៃទទួលសន្លឹកកិច្ចការ) រក្សាឱ្យបាននូវគោលការសុវត្ថិភាព និងអនាម័យ
- ធានាថាកូនៗបានរៀនតាមកាលវិភាគប្រចាំសប្តាហ៍ មានសន្លឹកកិច្ចការ ជាមួយនិងវីដេអូ អានសៀវភៅសិក្សាគោល ធ្វើសំណួរ លំហាត់ ឬចំណោទតាមមេរៀននីមួយៗ។

### ៣.៤ កិច្ចការរបស់សិស្ស និងក្រុមប្រឹក្សាកុមារ យុវជន

- បង្កើតក្រុមគេឡក្រោមផ្ទាល់ខ្លួនតាមថ្នាក់ដែលរៀន
- ករណីមាតាបិតាមិនអាចជួយបង្រៀនកូនៗបាន សិស្សដែលរៀនយឺតត្រូវសុំឱ្យមិត្តភក្តិរួមថ្នាក់ដែលរៀនពូកែជួយណែនាំនូវមេរៀនដែលមិនទាន់យល់។

## ៤- ការបង្រៀននិងរៀនពីចម្ងាយ និងតាមប្រព័ន្ធអេឡិចត្រូនិក

### ៤.១- ការបង្រៀននិងរៀនពីចម្ងាយ តាមរយៈការផ្តល់សន្លឹកកិច្ចការ

គ្រឹះស្ថានមធ្យមសិក្សាស្ថិតក្នុងតំបន់ដែលមានហានិភ័យនៃការរីករាលដាលនៃជំងឺកូវីដ-១៩ គ្រប់សាលាមធ្យមសិក្សាសាធារណៈអាចពិនិត្យលទ្ធភាពអនុវត្តការបង្រៀន និងរៀនពីចម្ងាយតាមរយៈការផ្តល់សន្លឹកកិច្ចការឱ្យសិស្សយកទៅស្វ័យសិក្សានៅផ្ទះ។ គណៈគ្រប់គ្រងសាលា និងលោកគ្រូ អ្នកគ្រូ គណៈកម្មការគ្រប់គ្រងសាលារៀនសហការជាមួយអាជ្ញាធរដែនដីភូមិ ឃុំ ត្រូវអនុវត្តដូចខាងក្រោម៖

- រៀបចំថតចម្លងសន្លឹកកិច្ចការដែលក្រសួង(នាយកដ្ឋានមធ្យមសិក្សា)បានផលិត និងផ្តល់ជូននាពេលកន្លងមក
- រៀបចំសង្ខេបមេរៀនជាជំនួយដល់ការសិក្សារបស់សិស្ស ដោយផ្តោតលើមុខវិជ្ជាកាតព្វកិច្ច
- កៀរគរថវិកាពីប្រភពនានារួមមានថវិកាដំណើរការសាលារៀន ថវិការបស់អង្គការដៃគូនានា ថវិកាដែលបានមកពីការចូលរួមរបស់សហគមន៍ សប្បុរសជន និងមាតាបិតា/អ្នកអាណាព្យាបាល សិស្សជាដើម ដើម្បីគាំទ្រដល់ការថតចម្លងសន្លឹកកិច្ចការចែកជូនសិស្សានុសិស្ស
- ធ្វើការបែងចែកវេនឱ្យសិស្សមកទទួលសន្លឹកកិច្ចការ ផ្តល់សន្លឹកកិច្ចការមកវិញនៅសប្តាហ៍បន្ទាប់ជាមួយនឹងការប្តូរសន្លឹកកិច្ចការថ្មីនៅសាលារៀន ដោយលៃពេលវេលាខុសៗគ្នាដើម្បីកាត់បន្ថយឱ្យបានជាអប្បបរមានូវចំនួននៃការជួបជុំ (គ្រូតាមមុខវិជ្ជាត្រូវមានវត្តមាននៅសាលារៀន)
- ចែកវេនឱ្យសិស្សមកទទួលសន្លឹកកិច្ចការ ផ្តល់សន្លឹកកិច្ចការមកវិញនៅសប្តាហ៍បន្ទាប់ ជាមួយនឹងការប្តូរសន្លឹកកិច្ចការថ្មីនៅសាលារៀន ដោយលៃពេលវេលាខុសៗគ្នាដើម្បីកាត់បន្ថយឱ្យបានជាអប្បបរមានូវចំនួននៃការជួបជុំ (គ្រូតាមមុខវិជ្ជាត្រូវមានវត្តមាននៅសាលារៀន)
- សិស្សធ្វើស្វ័យសិក្សា សន្លឹកកិច្ចការថតចម្លង ចំណែកគ្រូផ្ទៀងផ្ទាត់លទ្ធផលស្វ័យសិក្សានៅសាលារៀន
- គ្រូបង្រៀនតាមមុខវិជ្ជា និងគ្រូទទួលបន្ទុកថ្នាក់ត្រូវកែកិច្ចការ ពិនិត្យនិងផ្តល់យោបល់លើសន្លឹកកិច្ចការដែលសិស្សប្រគល់ជូន និងធ្វើការពន្យល់បន្ថែមដល់សិស្សនៅពេលពួកគេយកសន្លឹកកិច្ចការចាស់មកប្រគល់ និងទទួលសន្លឹកកិច្ចការ ថ្មីនៅសប្តាហ៍បន្ទាប់។

### ៤.២- ការបង្រៀននិងរៀនពីចម្ងាយតាមរយៈប្រព័ន្ធអេឡិចត្រូនិក

គ្រឹះស្ថានមធ្យមសិក្សាសាធារណៈស្ថិតក្នុងតំបន់ ដែលមានហានិភ័យខ្ពស់នៃការរីករាលដាលនៃជំងឺកូវីដ ១៩ ត្រូវពិនិត្យលទ្ធភាពអនុវត្តការបង្រៀននិងរៀនពីចម្ងាយតាមប្រព័ន្ធអេឡិចត្រូនិក។ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងលោកគ្រូ អ្នកគ្រូត្រូវអនុវត្តដូចខាងក្រោម៖

- ជំរុញឱ្យមានការរៀនពីចម្ងាយតាមប្រព័ន្ធផ្សព្វផ្សាយផ្លូវការ ដូចជា Facebook, YouTube, ទូរទស្សន៍ និងតាមរយៈ App ផ្លូវការនានា
- រៀបចំការបង្រៀនតាមកម្មវិធី Zoom, Google Meet និងតាមកម្មវិធីផ្សេងៗទៀតទៅតាមលទ្ធភាព និងសមត្ថភាព
- សិស្សធ្វើស្វ័យសិក្សាសន្លឹកកិច្ចការតាម Google Form ចំណែកគ្រូគ្រូផ្ទៀងផ្ទាត់លទ្ធផលស្វ័យសិក្សាតាមអនឡាញមាន Zoom ឬ Google Meet
- ផ្តល់និងកែសន្លឹកកិច្ចការ ក៏ដូចជាវីដេអូការបង្រៀន មេរៀនសង្ខេប តាមក្រុម ...Telegram ឬ Messenger
- ធ្វើការពន្យល់ និងបកស្រាយនូវចម្ងល់នានារបស់សិស្សតាមរយៈទូរស័ព្ទដោយផ្ទាល់ ឬ ក្រុម Telegram ឬ Messenger ជាដើម។

## ៥. ការវាយតម្លៃលទ្ធផលសិក្សា

គ្រឹះស្ថានមធ្យមសិក្សាសាធារណៈត្រូវអនុវត្តការប្រឡងប្រចាំខែតាមស្ថានភាព និងគ្រប់រូបភាព ដែលអាចអនុវត្តបាន ដោយយកលទ្ធផលពីការធ្វើតេស្តចាប់ពីខែកុម្ភៈ រហូតដល់ដំណាច់(វិច្ឆិកា)ឆ្នាំ២០២១។ ការវាយតម្លៃសមត្ថភាពសិស្សម្នាក់ៗទៅលើមុខវិជ្ជាដែលសាលារៀននីមួយៗបានបង្រៀន និងរៀន ហើយសិស្សត្រូវមានពិន្ទុគ្រប់មុខវិជ្ជា ដែលគ្រូបានបង្រៀនក្នុងខែ។ សម្រាប់ខែមេសា និងឧសភាត្រូវបូកសរុបធ្វើចំណាត់ថ្នាក់តែមួយខែ ដោយសរសេរថា ចំណាត់ថ្នាក់ខែមេសា និងឧសភា។

### ៥.១-ការប្រឡងប្រចាំខែ

គ្រឹះស្ថានមធ្យមសិក្សាត្រូវរៀបចំឱ្យមានលទ្ធផលសិក្សាតាមខែនីមួយៗ ដោយយកពិន្ទុតាមសប្តាហ៍បូកសរុបបញ្ចូលគ្នា ឬប្រឡងប្រចាំខែទៅតាមស្ថានភាពសាលារៀន។

- រយៈពេលប្រឡង និងរបបពិន្ទុ អនុវត្តតាមសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- ចំពោះមុខវិជ្ជាភាសាបរទេសពិន្ទុដែលត្រូវយកមកបូក គឺជាផលសង នៃពិន្ទុដែលសិស្សធ្វើបាន ដកនឹង ២៥។ ពិន្ទុនេះបូកជាមួយពិន្ទុមុខវិជ្ជាដទៃ រួចហើយទើបគណនារកមធ្យមភាគពិន្ទុប្រឡងឆមាសជាក្រោយ។

**បង្រៀន និងរៀនបាន**

- សម្រាប់ថ្នាក់ទី ៩ និងទី១២ សូមអនុវត្តដូចមានក្នុងសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី ៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- **មធ្យមភាគពិន្ទុប្រចាំខែ = ផលបូកពិន្ទុគ្រប់មុខវិជ្ជាចែកនឹងសន្ទស្សន៍ i (គិត៥០ពិន្ទុ)**

  **សម្គាល់៖** សន្ទស្សន៍ i = ៨.៤ (ថ្នាក់ទី៩) សន្ទស្សន៍ i = ១២.៥(ថ្នាក់ទី១២)
- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ និងទី១១សូមអនុវត្តដូចខាងក្រោម៖
  - ការរកសន្ទស្សន៍នៃមុខវិជ្ជានីមួយៗគឺ ស្មើនឹងពិន្ទុអតិបរមានៃមុខវិជ្ជានីមួយៗ ចែកនឹង ៥០
  - មធ្យមភាគពិន្ទុប្រចាំខែគឺ ស្មើនឹងផលបូកពិន្ទុគ្រប់មុខវិជ្ជាបានប្រឡង ចែកនឹងផលបូកនៃសន្ទស្សន៍គ្រប់មុខវិជ្ជាបានប្រឡង

$$\text{មធ្យមភាគពិន្ទុប្រចាំខែ} = \frac{\text{ផលបូកពិន្ទុជាក់ស្តែង (មុខវិជ្ជាបានប្រឡង)}}{\text{ផលបូកសន្ទស្សន៍ (មុខវិជ្ជាបានប្រឡង)}}$$

ក្រោយការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សប្រចាំខែនីមួយៗ បើពិនិត្យឃើញថាមានសិស្សរៀនយឺត គ្រូទទួលបន្ទុកថ្នាក់ត្រូវសហការជម្រាបព័ត៌មានទៅមាតាបិតា ឬអ្នកអាណាព្យាបាលឱ្យជួយណែនាំ និងពង្រឹងបន្ថែមទៀត កិច្ចការនេះត្រូវអនុវត្តន៍ឱ្យបានទៀងទាត់។

## ៥.២-ការប្រឡងប្រចាំឆមាស

**បង្រៀន និងរៀនបាន**

- សម្រាប់ថ្នាក់ទី៩ និងទី១២ សូមអនុវត្តដូចមានក្នុងសេចក្តីណែនាំលេខ ១៦ អយក.សណន ចុះថ្ងៃ ពុធ ទី ៥ រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១
- សម្រាប់ថ្នាក់ទី៧ ទី៨ ទី១០ និងទី១១សូមអនុវត្តដូចខាងក្រោម៖
  - **មធ្យមភាគពិន្ទុខែប្រចាំឆមាស=ផលបូកមធ្យមភាគពិន្ទុប្រចាំខែក្នុងឆមាសចែកនឹងចំនួនខែក្នុងឆមាស (គិត៥០ពិន្ទុ)**
  - ករណីពុំអាចដំណើរការប្រឡងឆមាស៖ ត្រូវយក **មធ្យមភាគពិន្ទុខែប្រចាំឆមាស** ធ្វើជា **មធ្យមភាគពិន្ទុប្រចាំឆមាស**
  - ករណីអាចដំណើរប្រឡងឆមាស៖ **មធ្យមភាគពិន្ទុប្រចាំឆមាស** ស្មើនឹង **ផលបូកមធ្យមភាគពិន្ទុខែប្រចាំឆមាស និងមធ្យមភាគពិន្ទុប្រឡងឆមាស** ចែកនឹង២។
  - **មធ្យមភាគពិន្ទុប្រចាំឆ្នាំ** ស្មើនឹង**ផលបូកមធ្យមភាគពិន្ទុប្រចាំឆមាសទី១** និង**មធ្យមភាគពិន្ទុប្រចាំឆមាសទី១** ចែកនឹង២។
- ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់លោកគ្រូ អ្នកគ្រូមាតាបិតា ឬអ្នកអាណាព្យាបាល និងគណៈកម្មការគ្រប់គ្រងសាលារៀន ឱ្យដឹងពីការធ្វើតេស្តឬប្រឡងបែបថ្មីដើម្បីចូលរួមជួយជំរុញការសិក្សាបន្ថែម
- ត្រូវផ្សព្វផ្សាយលទ្ធផលសិក្សាតាមប្រព័ន្ធអេឡិចត្រូនិច ឬផ្ញើសៀវភៅតាមដានការសិក្សារបស់សិស្សជូនទៅមាតាបិតា/អ្នកអាណាព្យាបាលសិស្សបានពិនិត្យ និងផ្តល់យោបល់
- ត្រូវរក្សាទុកសន្លឹកវិញ្ញាសា កិច្ចការតេស្ត និងលទ្ធផលសិក្សានៅទីចាត់ការសាលារៀន
- ត្រូវរក្សាទុកសៀវភៅបញ្ជីពិន្ទុ និងសៀវភៅហៅឈ្មោះសិស្សនៅទីចាត់ការសាលារៀន។

## ៦- ការគាំទ្រ និងអន្តរាគមន៍ផ្សេងៗ

- ផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈដល់គ្រូ ដូចជាផ្តល់ការរៀនសូត្រពីម្ងាយ តាមរយៈវីដេអូការបង្រៀនដែលបានផ្សព្វផ្សាយនាពេលកន្លងមក
- អាជ្ញាធរដែនដី(ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក) គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ ត្រូវលើកទឹកចិត្តសិស្សឱ្យបានចូលរៀន និងចូលរួមរៀនសូត្រ តាមគ្រប់រូបភាព

- អាជ្ញាធរដែនដី(ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ រដ្ឋបាលក្រុង ស្រុក) ជួយបង្កលក្ខណៈងាយស្រួល ដល់ការចុះបំពេញការងាររបស់លោកគ្រូ អ្នកគ្រូ ជាពិសេសការបង្រៀនតាមបណ្តុំ និងការបង្រៀន តាមរយៈសិស្សមកទទួលសន្លឹកកិច្ចការដោយផ្ទាល់នៅសាលារៀន
- វាយតម្លៃលើផលប៉ះពាល់នៃការសិក្សា និងកំណត់ចំណុចខ្វះខាតដែលសិស្សជួបប្រទះក្នុងការរៀនសូត្រដោយផ្តោតការយកចិត្តទុកដាក់លើក្រុមកុមារងាយរងគ្រោះ
- បន្តលើកទឹកចិត្តសិស្សដែលងាយរងគ្រោះតាមរយៈការផ្តល់ការគាំទ្រជាសម្ភារសិក្សា សម្លៀកបំពាក់ និងសម្ភារៈចាំបាច់ផ្សេងទៀត
- បន្តគាំទ្រដល់សិស្សរៀនយឺត ផ្អែកតាមលទ្ធផលតេស្តវាយតម្លៃ និងរៀបចំក្រុមសិស្សរៀនយឺតសម្រាប់ការបង្រៀនបន្ថែម
- បន្តទំនាក់ទំនងល្អជាមួយមាតាបិតា អ្នកអាណាព្យាបាលសិស្ស ដោយផ្តល់ព័ត៌មានអំពីការសិក្សា របស់កូនទៅពួកគាត់ជាប្រចាំ។

## ៧- ការពិនិត្យតាមដាន អធិការកិច្ច និងរបាយការណ៍

មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ត្រូវពិនិត្យតាមដានដំណើរការរបស់គ្រឹះស្ថានសិក្សា និងថ្នាក់រៀន និងអធិការកិច្ច ដើម្បីផ្តល់ការគាំទ្រ និងកែលម្អជាប្រចាំនៅតាមគ្រឹះស្ថានមធ្យមសិក្សា។

គណៈគ្រប់គ្រងសាលារៀនត្រូវរៀបចំ និងផ្ញើរបាយការណ៍ប្រចាំខែ ឆមាស ស្តីពីដំណើរការបង្រៀន និងរៀនតាមគ្រប់រូបភាពឱ្យបានទៀងទាត់តាមឋានានុក្រម។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាល ក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានមធ្យមសិក្សាសាធារណៈ បុគ្គលិកអប់រំ អាជ្ញាធរដែនដី មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់។/

ថ្ងៃ សុក្រ ១៣ កើត ខែ ជេស្ឋ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ